# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលនិងការដំឡើងប្រាក់បំណាច់មុខងារ ជូនមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលបៀវត្សមូលដ្ឋាននិងការបើកផ្តល់បៀវត្សដល់មន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៨៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលប្រព័ន្ធបៀវត្សរបស់នគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ ..**

អនុក្រឹត្យនេះមានគោលបំណងកែសម្រួល និង ដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីនគរបាលជាតិកម្ពុជា ដើម្បីធានាបាននូវសមធម៌ សង្គតិភាព ប្រសិទ្ធភាព និងការបង្កើនផលិតភាពការងារ។

**មាត្រា២ ..**

អនុក្រឹត្យនេះមានគោលដៅរៀបចំការកែសម្រួលនិងការដំឡើងប្រាក់បំណាច់មុខងាររបស់មន្ត្រីនគរបាលជាតិកម្ពុជា។

**មាត្រា៣ ..**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីនគរបាលជាតិកម្ពុជា។

**មាត្រា៤ ..**

ប្រាក់បំណាច់មុខងាររបស់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវបានរៀបចំបែងចែកតាមលំដាប់នៃមុខតំណែងមូលដ្ឋាននិងមុខតំណែងសមមូលជា១៦(ដប់ប្រាំមួយ)ថ្នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | មុខតំណែងមូលដ្ឋាន | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | អគ្គស្នងការ | ១ ៧៥០ ០០០ |
| ២ | អគ្គស្នងការរង | ១ ៤០០ ០០០ |
| ៣ | ប្រធាននាយកដ្ឋាន | ៧០០ ០០០ |
| ៤ | អនុប្រធាននាយកដ្ឋាន | ៦០០ ០០០ |
| ៥ | នាយការិយាល័យចំណុះនាយកដ្ឋាន | ៤២០ ០០០ |
| ៦ | នាយរងការិយាល័យចំណុះនាយកដ្ឋាន | ៣១០ ០០០ |
| ៧ | នាយផ្នែកចំណុះនាយកដ្ឋាន | ២៥០ ០០០ |
| ៨ | នាយរងផ្នែកចំណុះនាយកដ្ឋាន | ២១០ ០០០ |
| ៩ | នាយផ្នែកចំណុះអធិការដ្ឋាន | ១៩០ ០០០ |
| ១០ | នាយប៉ុស្តិ៍នគរបាលរដ្ឋបាល | ១៨៥ ០០០ |
| ១១ | នាយរងផ្នែកចំណុះអធិការដ្ឋាន | ១៨០ ០០០ |
| ១២ | នាយក្រុមតម្រួតបទបញ្ជា ខេត្ត-ក្រុង | ១៧០.០០០ |
| ១៣ | នាយរងក្រុមតម្រួតបទបញ្ជា ខេត្ត-ក្រុង | ១៦៥ ០០០ |
| ១៤ | នាយក្រុមនគរបាលការពារ | ១៦០ ០០០ |
| ១៥ | នាយរងក្រុមនគរបាលការពារ | ១៥៥ ០០០ |
| ១៦ | មន្ត្រីនគរបាលជាតិ | ១៥០ ០០០ |

ប្រាក់បំណាច់មុខងារខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦តទៅ។

**មាត្រា៥ ..**

មុខតំណែងដ៏ទៃទៀតដែលសមមូលនឹងមុខតំណែងមូលដ្ឋានខាងលើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ផ្អែកលើព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីសម្រេចស្តីពីការតែងតាំង។

**មាត្រា៦ ..**

មន្ត្រីនគរបាលជាតិកម្ពុជាដែលកំពុងស្ថិតក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងតំណែងនោះ។ ករណីមន្ត្រីនគរបាលជាតិកម្ពុជាដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតឱ្យជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយគត់។

**មាត្រា៧ ..**

ការកែប្រែចំនួនមុខតំណែងមូលដ្ឋានឬប្រាក់បំណាច់មុខងារដែលមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ ..**

មន្ត្រីនគរបាលជាតិកម្ពុជាដែលមានសិទ្ធទទួលប្រាក់បំណាច់មុខងារ ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- កំពុងបំពេញការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនិងកំពុងធ្វើដំណើរទៅកាន់មុខតំណែងនៅក្នុងឬក្រៅប្រទេស
- កំពុងបំពេញការសិក្សាក្នុងឬក្រៅប្រទេសតាមតម្រូវការរបស់នគរបាលជាតិ
- មន្ត្រីនគរបាលជាតិពលី មរណៈ ពិការ និវត្តជន បាត់បង់សមត្ថភាពការងារដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្ត
- មន្ត្រីនគរបាលជាតិដែលទទួលការអនុញ្ញាតច្បាប់ក្នុងធុរៈផ្ទាល់ រយៈពេលសម្រាកព្យាបាលជម្ងឺ និងបាត់ខ្លួនក្នុងបេសកកម្ម ។

**មាត្រា៩ ..**

ការបញ្ឈប់ការបើកផ្តល់ប្រាក់បំណាច់មុខងារ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងករណីដូចខាងក្រោម៖

- មន្ត្រីនគរបាលជាតិដែលសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- មន្ត្រីនគរបាលជាតិដែលមានប្រកាសបណ្តេញចេញពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- មន្ត្រីនគរបាលជាតិដែលអវត្តមានគ្មានការអនុញ្ញាតឬហួសកំណត់ដោយសម្អាងលើប្រធានស័ក្តិដែលមិនសមស្រប
- មន្ត្រីនគរបាលជាតិពលី មរណៈ ពិការ និវត្តជន បាត់បង់សមត្ថភាពការងារដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្តរួចហើយ
- មន្ត្រីនគរបាលជាតិដែលបាត់បង់ឋានន្តរស័ក្តិតាមសាលក្រមឬសាលដីការស្ថាពររបស់តុលាការ។

**មាត្រា១០ ..**

របបឧបត្ថម្ភផ្សេងៗរបស់មន្ត្រីនគរបាលជាតិកម្ពុជាក្រៅពីប្រាក់បំណាច់មុខងារ ត្រូវបន្តអនុវត្តរហូតដល់មានការកែប្រែជាថ្មី។

**មាត្រា១១ ..**

អនុក្រឹត្យលេខ២០៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីនគរបាលជាតិ អនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទនិងមន្ត្រីនគរបាលជាតិ និងអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទនិងមន្ត្រីនគរបាលជាតិ ត្រូវទុកជានិរាករណ៍ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

| **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** |
| --- | --- | --- |
| **សម្ដេចក្រឡាហោម ស ខេង** | **អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ